ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ០១ រោច ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៩*

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពីកិច្ចពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ជាមួយឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហរដ្ឋអាមេរិក**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

នាព្រឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម **Patrick Murphy** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា នាឱកាសដែលឯកឧត្តមឯកអគ្គរដ្ឋទូតទើបចូលកាន់ដំណែង ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម **Patrick Murphy** នាឱកាសដែលឯកឧត្តមត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិក តែងតាំងជាឯកអគ្គរដ្ឋទូតថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងសហរដ្ឋអាមេរិក បាននាំមកនូវលទ្ធផលប្រកបដោយផ្លែផ្កា ។ ជាក់ស្តែង, ចាប់តាំងពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០១៩ នេះ, សហរដ្ឋអាមេរិក បានផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ១ ៥០០ លានដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍នានានៅកម្ពុជា ដោយផ្តោតលើវិស័យអប់រំ សុខាភិបាល កសិកម្ម និងបរិស្ថាន ។ ជាមួយគ្នានេះ, ក្រុមហ៊ុនអាមេរិកជាច្រើនបានមកដាក់ទុនវិនិយោគនៅកម្ពុជាជាបន្តបន្ទាប់ ខណៈដែលទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរបានបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគីនេះ បានរួមចំណែកបង្កើតការងារ និងផ្តល់ប្រាក់ចំណូលជាច្រើនដល់ប្រជាជនកម្ពុជា ។

ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមរិក **Patrick Murphy** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងបន្តជួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា តាមរយៈការបន្តផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់កម្មវិធីសុខភាពសាធារណៈ និងការអប់រំ, កម្មវិធីកសិកម្ម និងបរិស្ថាន, កម្មវិធីដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ, ការផ្តល់ជំនួយបច្ចេកទេស និងការអភិវឌ្ឍធនធានមនុស្ស សំដៅរួមចំណែកដល់ការអភិវឌ្ឍនៅកម្ពុជា ។ ជាមួយគ្នានេះ,

រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងបន្តជួយផងដែរដល់វិស័យឯកជននៅកម្ពុជា តាមរយៈកម្មវិធីលើកកម្ពស់អភិបាលកិច្ច និងការបង្កើនកិច្ចសហប្រតិបត្តិការផ្នែកវិនិយោគ និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។

ជាមួយគ្នានេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានថ្លែងអំណរគុណរដ្ឋាភិបាលសហរដ្ឋ-អាមរិក ដែលបានជួយគាំទ្រ ដល់ការធ្វើកំណែទម្រង់នៅកម្ពុជា ជាពិសេស កំណែទម្រង់ខាងពន្ធដារ និងថវិកា ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានជម្រាបជូនឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកផងដែរថា រាជរដ្ឋាភិបាលកម្ពុជានឹងបន្តធ្វើកំណែទម្រង់លើកកម្ពស់អភិបាលកិច្ច, កែលម្អបរិយាកាសវិនិយោគ, សាងសង់ហេដ្ឋារចនាសម្ព័ន្ធ, អភិវឌ្ឍធនធានមនុស្ស, បង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីបន្តរក្សាកំណើនសេដ្ឋកិច្ចខ្ពស់នៅក្នុងរយៈពេលវែង សំដៅប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ឆ្លៀតក្នុងឱកាសនោះដែរ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនអាមេរិក ដែលបាននិងបន្តជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ហើយជូនពរឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក Patrick Murphy បំពេញបេសកកម្មការទូតនៅកម្ពុជា ប្រកបដោយជោគជ័យ ៕